**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៧. សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំហាត់សមយុទ្ធ និងជួយសង្គ្រោះពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៤២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលមាត្រា នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមតម្រូវការចាំបាច់

www.pheakdeylaw.com

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះ នៅពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **ញឹម វណ្ណដា** | ទេសរដ្ឋមន្ត្រី អនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | អនុប្រធាន |
| ៣-ឯកឧត្តម **ម៉ៅ ហាសវណ្ណាល់** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៤-ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥-ឯកឧត្តម **ខ្វិម យ៉ុនឡៀង** | ទីប្រឹក្សាសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | អនុប្រធាន |
| ៦-ឯកឧត្តម **ម៉ិន សម** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-ឯកឧត្តម **ហេង តៃគ្រី** | រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល នាយកមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ៨-ឯកឧត្តម **នឹម ច័ន្ទតារា** | អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩-ឯកឧត្តម **កែវ សារផល** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១០-ឯកឧត្តមឧត្តមសេនីយ៍ **ផាន់ ខួន** | អនុរដ្ឋលេខាធិការ នៃក្រសួងការពារជាតិ | សមាជិក |
| ១១-ឯកឧត្តមឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១២-ឯកឧត្តមឧត្តមសេនីយ៍ **ស៊ឹង សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| ១៣-ឯកឧត្តមឧត្តមសេនីយ៍ **យូ ស៊ុនឡុង** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៤-ឯកឧត្តមអភិបាលរាជធានីភ្នំពេញ | | សមាជិក |
| ១៥-ឯកឧត្តមអភិបាលខេត្តសៀមរាប | | សមាជិក |
| ១៦-ឯកឧត្តមអភិបាលក្រុងព្រះសីហនុ | | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ១៧-ឯកឧត្តមឧត្តមសេនីយ៍ **ម៉ៅ សុផាន់** | មេបញ្ជាការកងពលតូចលេខ ៧០ | សមាជិក |
| ១៨-ឯកឧត្តមឧត្តមសេនីយ៍ **ចាប ភក្តី** | មេបញ្ជាការកងពលតូចឆ័ត្រយោងលេខ ៩១១ | សមាជិក |
| ១៩- ឯកឧត្តម **ម៉ក់ ពេជ្ររិទ្ធ** | ប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០-លោកឧត្តមសេនីយ៍ **ថោង លឹម** | ប្រធាននាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២១-លោក **ខៀវ សំអាន** | ប្រធានការិយាល័យគយ និងរដ្ឋាករ ប្រចាំអាកាសយានដ្ឋានអន្តរជាតិ | សមាជិក |
| ២២-លោកឧត្តមសេនីយ៍ **ម៉ិន នី** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិក |
| ២៣-លោក **ម៉ិន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប | សមាជិក |
| ២៤-លោក **ហ៊ុន ឈឿន** | នាយកអាកាសយានដ្ឋានអន្តរជាតិ ក្រុងព្រះសីហនុ | សមាជិក |
| ២៥-លោកអគ្គនាយកក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ | | សមាជិក |
| ២៦-លោកអគ្គនាយកក្រុមហ៊ុនសេវាកម្មគ្រប់គ្រងចរាចរដែនអាកាស នៃព្រះរាជាណាចក្រកម្ពុជា | | សមាជិក |

**ប្រការ ២ :** គណៈកម្មាធិការសម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះ ពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ច :

-ដឹកនាំការងារធ្វើលំហាត់សមយុទ្ធជួយសង្គ្រោះយន្តហោះ និងអ្នកដំណើរតាមការកំណត់គ្រោងទុក

-ត្រៀមរៀបចំកម្លាំង សម្ភារៈ និងឧបករណ៍ ឱ្យបានគ្រប់គ្រាន់ក្នុងការអនុវត្តការងារជួយសង្គ្រោះ មុនពេលរៀបចំសមយុទ្ធ ក្នុងពេលកំពុងដំណើរការសមយុទ្ធ ក្រោយពេលការងារសមយុទ្ធត្រូវបានបញ្ចប់ និងពេលមានគ្រោះថ្នាក់យន្តហោះជាក់ស្តែង ឬ ជួបឧបទ្ទវហេតុផ្សេងៗ ដោយចៃដន្យកើតឡើងនៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ

-សហការជាមួយក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជំរុញឱ្យការងាររុករក ជួយសង្គ្រោះយន្តហោះ និងអ្នកដំណើរ នៅពេលជួបឧបទ្ទវហេតុខាងលើ

www.pheakdeylaw.com

-ធ្វើរបាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ក្រោយពេលធ្វើលំហាត់សមយុទ្ធ ឬក្រោយពេលសង្គ្រោះយន្តហោះ និងអ្នកដំណើរនៅពេលជួបឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះជាក់ស្តែង ។

**ប្រការ ៣ :** គណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ដោយប្រើប្រាស់មន្ត្រីទាំងអស់របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាដែលមានស្រាប់ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :** រាល់ការចំណាយសម្រាប់រៀបចំលំហាត់សមយុទ្ធ ជាបន្ទុករបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ និងក្រុមហ៊ុនសេវាកម្មគ្រប់គ្រងចរាចរដែនអាកាស នៃព្រះរាជាណាចក្រកម្ពុជា។
ចំពោះការចំណាយសង្គ្រោះ ពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះជាក់ស្តែង ជាបន្ទុករបស់រាជរដ្ឋាភិបាល ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ន្លែងទទួល**

សួងព្រះបរមរាជវាំង

រលេខាធិការដ្ឋានព្រឹទ្ធសភា

រលេខាធិការដ្ឋានរដ្ឋសភា

កាល័យសម្តេចនាយករដ្ឋមន្ត្រី

កាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

ប្រការ ៥

កិច្ច

សារ កាលប្បវត្តិ

www.pheakdeylaw.com